# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីការកាត់ទោសខ្មែរក្រហម តើជាការចាំបាច់ ដែលត្រូវកាត់ទោសឬទេ ហើយបើកាត់ទោសទៅ តើអាចមានសង្គ្រាមស៊ីវិលឬទេ ?

web site: hoksavann.org

ថ្ងៃទី៥ កុម្ភៈ ២០០៥

តាមការសាកសួរស្ទាបស្ទង់យោបល់មួយចំពោះប្រជាពលរដ្ឋខ្មែរ ក្នុងការកាត់ទោសខ្មែរក្រហមរបស់អង្គការមួយនៅភ្នំពេញបានបញ្ជាក់ថា ប្រជាពលរដ្ឋខ្មែរជាង៩០%ចង់ឲ្យកាត់ទោសខ្មែរក្រហម ។ ដូច្នេះការកាត់ទោសខ្មែរក្រហមជាការចាំបាច់ដែលត្រូវកាត់ទោស ដើម្បីរកយុត្តិធម៌ជូនប្រជាពលរដ្ឋរងគ្រោះ ។ ប្រទេសកម្ពុជាត្រូវអន្តរជាតិចោទថា ជាប្រទេសនិទណ្ឌភាព គឺអ្នកមានទោសឲ្យរួចខ្លួន មិនធ្វើទោសទៅតាមច្បាប់ ។

ចំពោះការកាត់ទោសខ្មែរក្រហមនេះ សូម្បីព្រះសង្ឃព្រះពុទ្ធសាសនាដែលកាន់ព្រះវិន័យដ៏តឹងរ៉ឹងក៏មានយោបល់ថាឲ្យកាត់ទោសដែរ ព្រោះការកាត់ទោសនេះពុំមែនមានន័យថា ចងពៀរជាមួយខ្មែរក្រហមឡើយ តែជាការរកយុត្តិធម៌តានផ្លូវច្បាប់អន្តរជាតិ ដូចព្រះសង្ឃមានកំហុសក្នុងព្រះវិន័យ ក៏ត្រូវទទួលទោសតាមកំហុសនេះដែរ ពុំអាចលើកលែងទោសបានឡើយ គឺត្រូវធ្វើកិច្ចទៅតាមព្រះវិន័យ។ យ៉ាងណាមិញ ផ្លូវអាណាចក្រក៏មានច្បាប់សំរាប់ការពារអ្នកធ្វើត្រូវ និងផ្តន្ទាទោសអ្នកធ្វើខុសដូចគ្នាដែរ ។ មួយទៀត កំហុសខ្មែរក្រហមពុំមែនជាកំហុសធម្មតាឡើយ ជាកំហុសប្រឆាំងនឹងមនុស្សជាតិ ។ ការកាត់ទោសមិនត្រឹមតែរកយុត្តិធម៌ជូនប្រជាពលរដ្ឋខ្មែរអ្នករងគ្រោះប៉ុណ្ណោះ លើសពីនេះទៅទៀត គឺដើម្បីទុកជាគំរូអាក្រក់ដល់អ្នកខាងក្រោយទៀត ។

★ ការកាត់ទោសខ្មែរក្រហមពុំមានកើតសង្គ្រាមស៊ីវិលឡើយ ព្រោះកូនចៅខ្មែរក្រហមតូចតាចថ្នាក់ក្រោម ដែលគ្រាន់តែធ្វើតាមបញ្ជាខ្មែរក្រហមថ្នាក់លើនោះពុំត្រូវកាត់ទោសទេ ហើយកូនចៅខ្មែរក្រហមតូចតាចទាំងនោះ ក៏ត្រូវរងគ្រោះដោយសារមេខ្មែរក្រហមធំៗទាំងនោះដែរ ។ ពួគេក៏ចង់ឲ្យគេរកយុត្តិធម៌ជូនបងប្អូនកូនចៅគេ ដែលត្រូវមេខ្មែរក្រហមយកទៅសម្លាប់ដូចបងប្អូនខ្មែរទូទៅដែរ ។ ខ្មែរក្រហមថ្នាក់ក្រោមពិតជាពុំគាំទ្រមេខ្មែរក្រហមដែលមានបាតដៃប្រឡាក់ឈាម ហើយដែលមានវ័យចាស់ជរាជិតស្លាប់នោះឡើយ ។ ប្រជាពលរដ្ឋខ្មែរដែលគេបង្ខំឲ្យធ្វើខ្មែរក្រហមនោះ ពិតជាពុំពេញចិត្តនឹងរបបកុម្មុយនិស្ត ហើយចង់ឲ្យគេកាត់ទោស មេខ្មែរក្រហមទាំងនោះឲ្យបានឆាប់រហ័ស ដើម្បីបិទទំព័រប្រវត្តិសាស្រ្តខ្មែរដ៏ខ្មៅងងឹតនេះ ។ ប្រជាពលរដ្ឋខ្មែរមានការនឿយណាយនឹងសង្គ្រាម ហើយចេញផុតពីរបបកុម្មុយនិស្តពុំចូលទៅកាន់កុម្មុយនិស្តវិញឡើយ ហើយជាពិសេសមិនត្រូវការធ្វើសង្គ្រាមបង្ហូរឈាម ដោយគ្រាន់តែជួយលុបលាងកំហុសរបស់ខ្មែរក្រហមប៉ុន្មាននាក់នោះឡើយ ។

★ ថវិកាដែលត្រូវចំណាយក្នុងការកាត់ទោសខ្មែរក្រហម តាមគម្រោងថាមានចំនួន៥៦លានដុល្លារ ខ្មែរត្រូវចេញ១៣លានដុល្លារ ក្រៅពីនោះទៅលើអង្គការសហប្រជាជាតិ ។ ថវិកាទាំងនោះ គេចំណាយសំរាប់កាត់ទោសខ្មែរក្រហម, ខ្លះថាគួរបង្វិលថវិកានោះទៅជួយសង្គ្រោះប្រជាពលរដ្ឋខ្មែរក្រីក្រវិញ, តើបានអ្វីបង្វិល ព្រោះថាបើមិនយកថវិកានេះទៅប្រើសំរាប់កាត់ទោសខ្មែរក្រហមទេ គេក៏មិនផ្តល់វិភាគទាននេះដែរ ។ ថវិកាដែលអន្តរជាតិជួយប្រជាពលរដ្ឋខ្មែរក្រីក្រមានចំនួនជាង៥០០លានដុល្លារៀងរាល់ឆ្នាំ ទាំងជំនួយគ្មានសំណងទាំងថវិកាឲ្យខ្ចី ។

បើថវិកាជាង៥០០លានដុល្លារមិនទាន់គ្រប់ ដោយយកមួយភាគចូលហោប៉ៅជនពុករលួយត្រូវសុំថវិកាបន្ថែម មិនត្រូវយកថវិកាដែលមានមុខសំរាប់កាត់ទោស ខ្មែរក្រហមយកទៅចំណាយរឿងផ្សេងខុសពីបំណងម្ចាស់អំណោយឡើយ ។ អន្តរជាតិកំពុងតែចាប់អារម្មណ៍នឹងផ្តល់ថវិកាឲ្យបានគ្រប់ចំនួន ដើម្បីឲ្យបានសំរេចក្នុងការកាត់ទោសនេះ បើមិនកាត់ទោសវិញ ថវិកានេះក៏គ្មានដែរ ដូច្នេះត្រូវខាតទាំងពីរផ្នែក គឺខាតថវិកាគេមិនផ្តល់ឲ្យផង ខាតរកយុត្តិធម៌ជូនអ្នករងគ្រោះផង តើថវិកាឯណាដែលសំរាប់បង្វិលជួយអ្នកក្រីក្រខ្មែរនោះ ។ ពុំមែនគេពុំគិតជួយអ្នកក្រីក្រខ្មែរទេ ប៉ុន្តែការកាត់ទោសនេះ ជាការចាំបាច់បំផុតខានមិនបាន ត្រូវតែហ៊ានចំណាយទើបសំរេចបំណងនេះ ។

★ អដ្ឋិធាតុរបស់ព្រះសង្ឃនិងប្រជាពលរដ្ឋខ្មែរ ដែលត្រូវខ្មែរក្រហមធ្វើគតនិងសម្លាប់ត្រូវតែរក្សាទុក ដើម្បីជាភស្តុតាងជាក់ស្តែងក្នុងការកាត់ទោសខ្មែរក្រហម ។ អដ្ឋិធាតុទាំងនោះត្រូវបូជាឬត្រូវរក្សាទុកតទៅទៀតត្រូវសំរេចពីប្រជាពលរដ្ឋខ្មែរ ក្រោយពេលដែលកាត់ទោសខ្មែរក្រហមរួចហើយ ។ បដិសន្ធិវិញ្ញាណរបស់ព្រះសង្ឃនិងពលរដ្ឋខ្មែរដែលខ្មែរក្រហមធ្វើគតនិងសម្លាប់ បានចាប់បដិសន្ធិក្នុងភពថ្មីរួចហើយ គឺចាប់បដិសន្ធិភ្លាមតាំងពីជីវិតត្រូវរលត់ម្ល៉េះ ចាស់ពីបូរាណប្រៀបការចាប់បដិសន្ធិដូចជាដង្កូវបាក់ខ្លួង មុននឹងលែងជើងក្រោយ ត្រូវតោងជើងមុខឲ្យជាប់សិន ។ បានសេចក្តីថា មុននឹងដាច់ខ្យល់ស្លាប់បានតោងបដិសន្ធិចិត្តរួចហើយ ទើបដាច់ខ្យល់ស្លាប់ហើយ ក៏កើតតាមការតោងយកបដិសន្ធិចិត្តមុនដាច់ខ្យល់ស្លាប់នោះឯង ។ ដូច្នេះពុំមែនវិញ្ញាណរបស់អ្នកស្លាប់នៅវិលវល់ជាមួយអដ្ឋិធាតុនោះឡើយ ។ អដ្ឋិធាតុទាំងនេះទុកដូចជា អង្កត់អុសជាធាតុទឹកដីភ្លើងខ្យល់ប៉ុណ្ណោះនេះពោលតាមគម្ពីរអភិធម្មនៃព្រះពុទ្ធសាសនា។ បើមិនបានកាត់ទោសក្នុងតុលាការអន្តរជាតិ ដែលខ្មែរស្រឡាញ់យុត្តិធម៌ចង់បានទេ ក៏គួរកាត់ទោសក្នុងតុលាចំរុះនេះ ដោយជួយជម្រុញឲ្យមានភាពឯករាជ្យដែលអាចទទួលយកបានប្រសើរជាងមិនបានកាត់ទោសដែរ។

★ បញ្ហាកូនខ្មែរក្រហមទៅគាំទ្រខ្មែរ ក្រហមកុំឲ្យកាត់ទោសរហូតរត់ចូលព្រៃ ត្រូវចប់ពុំមានកើតមានដូច្នេះឡើយ ។ ផ្ទុយទៅវិញ គួរព្រួយបារម្ភចំពោះភាក្រីក្រ របស់ប្រជាពលរដ្ឋបច្ចុប្បន្ននេះវិញព្រោះ មនុស្សកាលណាគ្មានអ្វីទទួលទានគ្មានទីលំនៅស្នាក់នៅ តែងតែរកមធ្យោបាយគ្រប់យ៉ាង ដើម្បីការរស់នៅរបស់ខ្លួន ។ យ៉ាងណាមិញពលរដ្ឋខ្មែរសព្វថ្ងៃនេះ មានចំណូលមិនដល់១ដុល្លារអាមេរិកផងក្នុង១ថ្ងៃ ។ ចំនួយបរទេសតាំងពីឆ្នាំ១៩៩៣មក មានចំនួនពី៥០០ទៅ៦០០ដុល្លារក្នុងមួយឆ្នាំ តែជីវភាពរបស់ប្រជាពលរដ្ឋខ្មែរកាន់តែក្រទៅៗ តើបណ្តាលមកពីហេតុអ្វី ។ អំពើពុករលួយមានពាសពេញប្រទេស, ការរំលោភយកដីរបស់ប្រជាពលរដ្ឋពីអ្នកកាន់អំណាចមានគ្រប់តំបន់, ពេលដោះស្រាយបញ្ហាតុលាការពុំមានយុត្តិធម៌, អំពើជួញដូរមនុស្សមានកាន់តែច្រើនឡើងៗ ។ អ្នកមាននិងអ្នកក្រឃ្លាតគ្នាកាន់តែឆ្ងាយទៅៗ ទាំងអស់នេះហើយដែលគួរឲ្យព្រួយបារម្ភ តើប្រជាជនអ្នកក្រីក្រទាំងនោះនឹង ក្រោកឡើងធ្វើអ្វីនៅអនាគត ដើម្បីលើកតម្កើងជីវភាពរបស់ខ្លួន និងប្រឆាំងការរំលោភរបស់អ្នកកាន់

អំណាច ។ ការជិះជាន់និងអំពើអយុត្តិធម៌ក្នុងសង្គមនឹងធ្វើឲ្យ ប្រជាជនរើបំរះ បើពុំរត់ចូលព្រៃម៉ាគីបង្កើតសង្គ្រាមស៊ីវិលទេ ក៏បង្កើតការចលាចលប្រឆាំងនឹងរដ្ឋាភិបាល ដែលនឹងបង្កើតអស្ថេរភាពខាងផ្លូវនយោបាយដែរ ។ ដើម្បីចៀសវាងព្រឹត្តិការណ៍នេះ មានតែធ្វើឲ្យប្រទេសមានយុត្តិធម៌ក្នុងសង្គម បំបាត់ការជិះជាន់ពីអ្នកកាន់អំណាច ជាពិសេសត្រូវបំបាត់ភាពក្រីក្រ ដោយលើកតម្កើងឋានៈជីវភាពរបស់ប្រជាពលរដ្ឋឲ្យកាន់តែខ្ពស់ឡើង ។៚

❑